# ត្រៀមខ្លួនជាស្រេចដើម្បីទៅ ចុះឈ្មោះ និង បោះឆ្នោត។



ELECTORAL COMMISSION
TE KAITIAKI TAKE KŌWHIRI

## ហេតុអ្វីត្រូវមកចុះឈ្មោះបោះឆ្នោត?

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ អ្នកត្រូវបញ្ចេញមតិក្នុងការបោះឆ្នោតសកល ការបោះឆ្នោតក្នុងមូលដ្ឋាន និងការបោះឆ្នោតប្រជាមតិ។ ការបោះឆ្នោតគឺជាឱកាសដែលអ្នកអាចជ្រើសរើសអ្នកតំណាងមួយរូបក្នុងការបញ្ចេញមតិអំពីបញ្ហាដែលអ្នកយកចិត្តទុកដាក់។

**អ្នកអាចប្រាកដថាសំឡេងរបស់អ្នកត្រូវបានស្តាប់ឮតាមរយៈការចុះឈ្មោះបោះឆ្នោត។**

## តើនរណាខ្លះអាចចុះឈ្មោះបោះឆ្នោតបាន?

អ្នក *ត្រូវតែ* ចុះឈ្មោះបោះឆ្នោត ប្រសិនបើអ្នក៖

- **មានអាយុ 18 ឆ្នាំឡើង ហើយ**
- **គឺជាពលរដ្ឋនូវែលហ្សេឡង់ ឬជាអ្នកមានទីលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសនូវែលហ្សេឡង់ និង**
- **បានរស់នៅក្នុងប្រទេសនូវែលហ្សេឡង់ជាប់រហូតលើសពីមួយឆ្នាំ នៅអំឡុងពេលណាមួយក្នុងជីវិតរបស់អ្នក។**

ប្រសិនបើអ្នកជាជនជាតិអូស្ត្រាលី Cook Islands Maori, Niuean ឬ Tokelauan អ្នកអាចចុះឈ្មោះបាន ប្រសិនបើអ្នកបានរស់នៅក្នុងប្រទេសនូវែលហ្សេឡង់រយៈពេល 12 ខែជាប់គ្នា។

ប្រសិនបើអ្នករស់នៅក្រៅប្រទេស អ្នកអាចចុះឈ្មោះបោះឆ្នោតបាន ប្រសិនបើអ្នក៖

- **គឺជាពលរដ្ឋនូវែលហ្សេឡង់ដែលបានរស់នៅក្នុងប្រទេសនូវែលហ្សេឡង់នៅក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ឬ**
- **គឺជាអ្នកមានសិទ្ធិរស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសនូវែលហ្សេឡង់ដែលបានរស់នៅក្នុងប្រទេសនូវែលហ្សេឡង់នៅក្នុងរយៈពេលដប់ពីរខែកន្លងមកនេះ។**

អ្នកអាចចុះឈ្មោះបាន នៅពេលអ្នកមានអាយុ 17 ឆ្នាំ។ នៅពេលអ្នកមានអាយុ 18 ឆ្នាំ អ្នកនឹងត្រូវបានចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ ហើយអ្នកនឹងត្រៀមរួចរាល់ក្នុងការបោះឆ្នោត។

## តើខ្ញុំត្រូវចុះឈ្មោះដោយរបៀបណា?

មានភាពងាយស្រួលក្នុងការចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នក។ អ្នកអាច៖

- ចូលទៅកាន់ **vote.nz**
  ហើយប្រើប័ណ្ណបើកបរនូវែលហ្សេឡង់
  លិខិតឆ្លងដែននូវែលហ្សេឡង់
  ឬអត្តសញ្ញាណដែលបានបញ្ជាក់ពី RealMe
  ដើម្បីចុះឈ្មោះតាមអ៊ីនធឺណិត
- ហៅទូរសព្ទឥតគិតថ្លៃទៅលេខ **0800 36 76 56**
  ហើយស្នើសុំឲ្យផ្ញើទម្រង់បែបបទមកអ្នក

នៅពេលអ្នកបានចុះឈ្មោះរួចហើយ នោះឈ្មោះរបស់អ្នកនឹងមានលើបញ្ជីឈ្មោះអ្នកបោះឆ្នោត។ អ្នកត្រូវតែមានឈ្មោះលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដើម្បីបោះឆ្នោតបាន។

អ្នកចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នក
នៅរៀងរាល់ពេលដែលអ្នកផ្លាស់ប្តូរទីលំនៅ។

## ការចុះឈ្មោះបោះឆ្នោត ប្រសិនបើអ្នកជាជនជាតិដើមភាគតិច Māori

ប្រសិនបើអ្នកមានដើមកំណើតជាជនជាតិដើមភាគតិច Māori ហើយចុះឈ្មោះបោះឆ្នោតជាលើកដំបូង អ្នកអាចធ្វើការជ្រើសរើសដ៏សំខាន់មួយ។ អ្នកត្រូវសម្រេចថាតើអ្នកចង់មានឈ្មោះលើបញ្ជីឈ្មោះអ្នកបោះឆ្នោតមួយណា៖ បញ្ជីឈ្មោះអ្នកបោះឆ្នោតសកល ឬបញ្ជីឈ្មោះអ្នកបោះឆ្នោត Māori។

ជម្រើសរបស់អ្នកមានឥទ្ធិពលដល់អ្នកបោះឆ្នោតដែលអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតសកល។

ប្រសិនបើអ្នកជ្រើសរើសយកបញ្ជីឈ្មោះអ្នកបោះឆ្នោតសកល អ្នកនឹងបោះឆ្នោតជ្រើសរើសបេក្ខភាពនៅក្នុងក្រុមអ្នកបោះឆ្នោតសកល។ ប្រសិនបើអ្នកជ្រើសរើសយកបញ្ជីឈ្មោះអ្នកបោះឆ្នោត Māori អ្នកនឹងបោះឆ្នោតជ្រើសរើសបេក្ខភាពនៅក្នុងក្រុមអ្នកបោះឆ្នោត Māori។ អ្នកអាចបោះឆ្នោតសម្រាប់បញ្ជីឈ្មោះគណបក្សនយោបាយដដែលនោះណាមួយក៏បាននៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលអ្នកមានឈ្មោះនៅលើនោះ។

បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលអ្នកជ្រើសរើស អាចមានឥទ្ធិពលទៅលើរបៀបដែលអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតថ្នាក់មូលដ្ឋាន។ ប្រសិនបើអ្នកមានឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត Māori ហើយអាជ្ញាធរមូលដ្ឋានរបស់អ្នកមានតំបន់ ឬមណ្ឌល Māori នោះ អ្នកនឹងត្រូវបោះឆ្នោតជ្រើសរើសបេក្ខភាពនៅក្នុងតំបន់ Māori។

ប្រសិនបើអ្នកផ្លាស់ប្តូរគំនិតនៅពេលដែលអ្នកបានជ្រើសរើសបញ្ជីឈ្មោះអ្នកបោះឆ្នោតរួចហើយ (បញ្ជីឈ្មោះអ្នកបោះឆ្នោត Māori ឬបញ្ជីសកល) អ្នកអាចផ្លាស់ប្តូរបញ្ជីឈ្មោះអ្នកបោះឆ្នោតបាននៅពេលមានជម្រើសការបោះឆ្នោត Māori ដែលនឹងត្រូវធ្វើឡើងរៀងរាល់ 5 ឆ្នាំម្តងប៉ុណ្ណោះ។

## ត្រូវការជំនួយក្នុងការចុះឈ្មោះបោះឆ្នោតឬ?

អ្នកអាចសាកសួរនរណាម្នាក់ដែលអ្នកស្គាល់ ដូចជាមិត្តភក្តិ ឬសមាជិកគ្រួសារ ឬអ្នកអាចស្នើសុំមន្ត្រីចុះបញ្ជីអ្នកបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកឲ្យជួយអ្នកបំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោតរបស់អ្នក ឬបំពេញទម្រង់បែបបទរបស់អ្នកឲ្យអ្នក។

អ្នកត្រូវចុះហត្ថលេខាលើទម្រង់បែបបទ។

ប្រសិនបើអ្នកស្គាល់នរណាម្នាក់ដែលមិនអាចបំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទចុះឈ្មោះបោះឆ្នោតរបស់ពួកគេដោយសារតែមានបញ្ហាខាងរាងកាយ ឬផ្លូវចិត្ត អ្នកអាចជួយពួកគេបាន។

សូមចូលទៅកាន់ **vote.nz** ដើម្បីស្វែងយល់បន្ថែមអំពីការជួយនរណាម្នាក់ក្នុងការចុះឈ្មោះបោះឆ្នោត។

## ព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកឬ?

ប្រសិនបើអ្នកមានក្តីកង្វល់អំពីសុវត្ថិភាពរបស់អ្នក ឬគ្រួសាររបស់អ្នក អ្នកអាចស្នើសុំឲ្យដាក់ឈ្មោះលើបញ្ជីសម្ងាត់មិនផ្សព្វផ្សាយបាន។ យើងនឹងរក្សាព័ត៌មានលម្អិតនៃការចុះឈ្មោះបោះឆ្នោតរបស់អ្នកឲ្យមានសុវត្ថិភាព ហើយយើងនឹងមិនផ្តល់ព័ត៌មាននេះទៅឲ្យនរណាម្នាក់ឡើយ។

សូមប្រឹក្សាជាមួយមន្ត្រីចុះបញ្ជីអ្នកបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក ដោយចូលទៅកាន់ **vote.nz** ឬទូរសព្ទទៅលេខ **0800 36 76 56** ដើម្បីទទួលព័ត៌មានបន្ថែម ព្រមទាំងទម្រង់បែបបទពាក្យសុំ។

## ត្រូវការព័ត៌មានបន្ថែមឬ?

សម្រាប់ព័ត៌មានបន្ថែមអំពីការចុះឈ្មោះបោះឆ្នោត
និងការបោះឆ្នោត៖

- ចូលទៅកាន់ **vote.nz**
- ចូលទៅកាន់ **facebook.com/ivoteNZ**

ព័ត៌មានអំពីការចុះឈ្មោះបោះឆ្នោត
និងការបោះឆ្នោតមានផ្សព្វផ្សាយជា 27 ភាសានៅលើគេហទំព័រ **vote.nz**។

ELECTORAL COMMISSION
TE KAITIAKI TAKE KŌWHIRI

ROE47 23/04/20_Khmer